# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់
# ស្ដីពី
# រយៈពេលនៃការឃុំខ្លួនជាបណ្ដោះអាសន្ន

**មាត្រា ១** រយៈពេលនៃការឃុំខ្លួនជាបណ្ដោះអាសន្ន ទោះស្ថិតនៅក្នុងករណីណាក៏ដោយមិនត្រូវឱ្យហួសពីបួនខែទេ ។ ប៉ុន្តែតាមការសម្រេចរបស់ចៅក្រមដែលមានមូលហេតុច្បាស់លាស់រយៈពេលនេះអាចបន្តដល់ប្រាំមួយខែបាន ប្រសិនបើមានការចាំបាច់សម្រាប់ធ្វើការស៊ើបអង្កេត ។

ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដូចមានចែងក្នុងអនុសញ្ញានានារបស់អង្គការសហប្រជាជាតិដែលកម្ពុជាជាហត្ថលេខី ការឃុំខ្លួនបណ្ដោះអាសន្នខាងលើនេះអាចពន្យាពេលមួយឆ្នាំម្ដងៗ ប៉ុន្តែរយៈពេលនៃការពន្យានេះមិនត្រូវឱ្យលើសពីបីឆ្នាំឡើយ ។

**មាត្រា ២** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** ច្បាប់នេះត្រូវ ប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៩ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី ២ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៩

**ប្រធានរដ្ឋសភា**

**ព្រះហស្ថលេខា និងត្រា**

**នរោត្តម រណឫទ្ធិ**